ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៩៧......សហវ

# សារាចរ
## ស្តីពី
## អត្ថប្រយោជន៍ទទួលបានពីការវាយតម្លៃកម្រិតអនុលោមភាពសារពើពន្ធ

អនុលោមតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ និងប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានពិនិត្យនិងវាយតម្លៃទៅលើកម្រិតអនុលោមភាពសារពើពន្ធ ដោយចែកជាបីប្រភេទគឺ មាស (អនុលោមភាពខ្ពស់) ប្រាក់ (អនុលោមភាពមធ្យម) និង សំរិទ្ធ (អនុលោមភាពទាប)។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការកំណត់នូវអត្ថប្រយោជន៍ពីការទទួលបានចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធទាំងបីប្រភេទ ដូចខាងក្រោម ÷

**១. ប្រភេទមាស ÷**

អ្នកជាប់ពន្ធប្រភេទមាស ត្រូវទទួលបាន÷

- វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ដែលមានសុពលភាព ២ ឆ្នាំ
- ការបង្វិលសងអាករលើតម្លៃបន្ថែមនូវទឹកប្រាក់ក្រោមចំនួន ៥០០ លានរៀល ដោយមិនចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន
- ការធ្វើសវនកម្មពេញលេញក្នុងរយៈពេល ២ ឆ្នាំម្តង ដោយមិនចាំបាច់ធ្វើសវនកម្មមានកម្រិត ឬសវនកម្មលើលិខិតស្នាម វៀរលែងតែមានការស្នើសុំពីអ្នកជាប់ពន្ធ។

**២. ប្រភេទប្រាក់ ÷**

អ្នកជាប់ពន្ធប្រភេទប្រាក់ ត្រូវទទួលបាន÷

- វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ដែលមានសុពលភាព ២ ឆ្នាំ
- ការបង្វិលសងអាករលើតម្លៃបន្ថែមនូវទឹកប្រាក់ក្រោមចំនួន ២០០ លានរៀល ដោយមិនចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន
- ការធ្វើសវនកម្មពេញលេញក្នុងរយៈពេល ២ ឆ្នាំម្តង និងសវនកម្មមានកម្រិត ក្នុងរយៈពេល ១ ឆ្នាំម្តង ដោយមិនចាំបាច់ធ្វើសវនកម្មលើលិខិតស្នាម វៀរលែងតែមានការស្នើសុំពីអ្នកជាប់ពន្ធ។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**៣. ប្រភេទសំរិទ្ធ ÷**

អ្នកជាប់ពន្ធប្រភេទសំរិទ្ធអាចទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ដែលមានសុពលភាព ២ ឆ្នាំ ហើយត្រូវអនុវត្តកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ